# អ្នកនាំសារ
The Messenger

19

ខែ មករា ឆ្នាំ ២០០៥- ព័ត៌មានពីព្រះសហគមន៍កាតូលិក




## អាពាហ៍ពិពាហ៍

# ធំនៅតែមិនធំជាងនាទី?



សង្គមស៊ីវិល និងគ្រោះរាំងស្ងួតឆ្នាំ២០០៤

ទំព័រ ៦



អំពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

ទំព័រ ៨

សេរីភាពរើសគូស្រករ នៃយុវជនសម័យទំនើប

ទំព័រ ៣

# តើនំនៅតែមិនធំជាងនាឡិឬ?

**នៅក្នុងសង្គមខ្មែរ ពិធីអាពាហ៍ពិពាហ៍ដើរតួយ៉ាងសំខាន់ដើម្បីឱ្យមានការទទួលស្គាល់ពីញាតិមិត្តជិតខាង។ សម័យនេះ កូនប្រុសកូនស្រីហាក់ដូចជាមានសិទ្ធិគ្រប់គ្រាន់ក្នុងការជ្រើសរើសគូស្រករខ្លួនឯង ផ្ទុយពីសម័យបុរាណដែលមិនអនុញ្ញាតឱ្យធ្វើបែបនេះទេ។**



ពិធីអាពាហ៍ពិពាហ៍គ្រិស្តសាសនាតាមប្រពៃណីខ្មែរនៅព្រះសហគមន៍ផ្សារតូច រាជធានីភ្នំពេញ។

### នំមិនធំជាងនាឡិមានន័យដូចម្តេច?

នាឡិគ្រាន់តែជាវត្ថុម្យ៉ាងដែលគេប្រើសំរាប់ធ្វើនំតែប៉ុណ្ណោះ ហើយនំមិនអាចធំជាងនាឡិបានទេ។ ប៉ុន្តែ បើយើងក្រលេកមើលមកក្នុងសង្គមមនុស្សវិញ យើងអាចឱ្យនិយមន័យមួយផ្សេងពីនេះ បានន័យថាៈ នៅសម័យរបបមាតាធិបតេយ្យ ឬរបបឪពុកម្តាយធិបតេយ្យ គឺឪពុកម្តាយមានសិទ្ធិធំគ្រប់គ្រងទៅលើកូនប្រុស និងកូនស្រី។ ជាពិសេសកូនស្រីតែម្តងដែលជាជនរងគ្រោះ មានន័យថាឪពុកម្តាយប្រៀបដូចជានាឡិមួយ ហើយកូនស្រីប្រៀបដូចជានំ។ ជាក់ស្តែងរឿងទុំទាវរបស់អ្នកនិពន្ធខ្មែរភិក្ខុសោមក៏បានឆ្លុះបញ្ចាំងឱ្យឃើញច្បាស់នូវទិដ្ឋភាពសង្គមខ្មែរ នាសតវត្សរ៍ទី១៧។ យាយផាន់ក៏ដូចជាម្តាយនៃគ្រួសារដទៃទៀតបានប្រើសិទ្ធិអំណាចរបស់គាត់ ដោយមិនឱ្យនាងទាវរៀបការជាមួយទុំបាន ទោះបីជាស្នេហារបស់ពួកគេស្មោះស្ម័គ្រនឹងគ្នាយ៉ាងណាក៏ដោយ។

### មតិផ្សេងៗចំពោះទស្សនៈនេះ

មកដល់បច្ចុប្បន្ននេះ ថ្វីត្បិតតែមិនទាន់មានការសិក្សាជាផ្លូវការណាមួយអំពីគំនិតអភិរក្សនិយមនេះ ក៏តាមរយៈការមើលឃើញជាក់ស្តែងបង្ហាញឱ្យឃើញថា ទស្សនៈអភិរក្សនេះនៅមានឥទ្ធិពលនៅតាមទីជនបទនៅឡើយ។

ចំពោះការរើសគូស្រករនេះ មានទស្សនៈផ្សេងៗដែលផ្ទុយគ្នា។ ចំពោះលោក ពុធ សុភ័ក្រ្ត គាត់យល់ស្របទៅលើទស្សនៈនៃការរៀបចំទុកដាក់កូនចៅដោយឪពុកម្តាយ។ លោកបានបញ្ជាក់ថាៈ “ខ្ញុំមានជំនឿជឿជាក់ទៅលើតួនាទីរបស់ឪពុកម្តាយ ព្រោះគាត់មានបទពិសោធន៍ច្រើននៅក្នុងជីវិត។ ពួកគាត់ដឹងអ្វីដែលល្អ និងអ្វីដែលអាក្រក់”។ ផ្ទុយទៅវិញ កញ្ញាពិដោរមានគំនិតប្រឆាំងទាំងស្រុងចំពោះទស្សនៈខាងលើនេះ។ នាងបានបញ្ចេញនូវប្រតិកម្មថាៈ ”ការជ្រើសរើសគូស្រករដោយខ្លួនឯងមានលក្ខណៈល្អជាង ពីព្រោះថាការដែលអាចរស់នៅជាមួយគ្នាបាន ប្រកបដោយសេចក្តីសុខនោះ វាអាស្រ័យទៅលើសាមីខ្លួនទាំងសងខាង។ ទាំងពីរនាក់ត្រូវចេះស្រលាញ់គ្នា និងស្គាល់ចិត្តគ្នាទៅវិញទៅមកមុនពេលរៀបការ”។

### នំមិនធំជាងនាឡិនៅតែលងអារម្មណ៍យុវជន

បើសម្លឹងមើលឱ្យឆ្ងាយផុតពីគំនិតខាងលើ រឿងពិតជាក់ស្តែងមួយរបស់អ្នកនាងនីន គឺអាចជាកញ្ចក់ឆ្លុះបញ្ចាំងនូវទិដ្ឋភាពជាក់ស្តែងក្នុងសង្គមខ្មែរ។ នីនគឺជានារីម្នាក់ដែលត្រូវបានឪពុកម្តាយចាប់បង្ខំឱ្យរៀបការទាំងនាងកំពុងតែមានចិត្តចង់រៀនបន្ត ប៉ុន្តែ នាងមិនអាចប្រកែកបានឡើយ។ ការដែលនាងយល់ព្រមតាមពួកគាត់នោះគឺជាកាតព្វកិច្ចក្នុងការសងគុណ។ ទោះបីអ្វីៗបានកន្លងផុតទៅហើយ ប៉ុន្តែ នីននៅតែប៉ងប្រាថ្នាចង់បានសិទ្ធិសេរីភាពមួយ។ នាងបាននិយាយថាៈ “ខ្ញុំពុំយល់ស្របជាមួយនឹងការរៀបការ ដោយមានឪពុកម្តាយជាអ្នករៀបចំឡើយ ពីព្រោះធ្វើដូច្នេះប្រៀបដូចជាការគាបសង្កត់សិទ្ធិសេរីភាពរបស់កូនៗពេក”។ មកទល់នឹងពេលនេះ រឿងមួយដែលនាងនៅតែសោកស្តាយនោះ គឺការបរាជ័យក្នុងការកសាងជីវិតគ្រួសារជាមួយនឹងសង្សាររបស់នាង។

រឿងពិតមួយនេះគឺជាឧទាហរណ៍ជាក់ស្តែងមួយសំរាប់យុវវ័យ។ ចំណែករឿងទុំទាវអាចចាត់ទុកបានជាបទពិសោធន៍មួយយ៉ាងធំបំផុតសំរាប់កុលបុត្រកុលធីតាខ្មែរ។ ជាធម្មតា ក្នុងប្រទេសមួយ

### អាពាហ៍ពិពាហ៍ត្រូវការចំណាយច្រើន?

គេមិនអាចកំណត់ថា ថវិកាប៉ុន្មានអាចរៀបពិធីអាពាហ៍ពិពាហ៍បាននោះទេ។ អាពាហ៍ពិពាហ៍តូចល្មមត្រូវការថវិកាប្រហែលជាង ១០០០ដុល្លារ។ គេត្រូវការចំណាយលើការជួលសំលៀកបំពាក់ សំអាងការ ជាងថតរូបវីដេអូ ជំនូនផ្លែឈើ ចិញ្ចៀនសំរាប់កូនកំលោះកូនក្រមុំ និងអាហារទទួលភ្ញៀវពេលល្ងាចដែលអាស្រ័យលើតំលៃតុតាមមុខអាហាររបស់ភោជនីយដ្ឋាន។



Photo: Fr. Franco

តំបន់មួយ ឬក្នុងសហគមន៍មួយតែងតែមាននូវទំនៀមទំលាប់របស់ខ្លួន ប៉ុន្តែ ការប្រកាន់ខ្ជាប់នូវទំនៀមទំលាប់មួយដែលគ្របសង្កត់ ឬចាស់គំរិលពេកនោះ ក៏នាំឱ្យមានបញ្ហាផងដែរ។ យាយផាន់ ក្នុងរឿងទុំទាវបានប្រើទស្សនៈ ធំមិនធំជាងនាឡិនេះ គាបសង្កត់មកលើកូន ដែលធ្វើឱ្យកើតមាននូវវិប្បដិសារីមួយយ៉ាងធំឈានទៅដល់សោកនាដកម្មបាត់បង់ជីវិតរបស់នាងទាវ និងនេនទុំ។

នេះជាបញ្ហាមួយដែលមាននៅក្នុងសង្គមខ្មែរតាំងពីសម័យមុន និងក៏នៅសេសសល់មកដល់សម័យបច្ចុប្បន្ននេះដែរ។ ថ្វីត្បិតឪពុកម្តាយជាអ្នកមានគុណផ្តល់កំណើតដល់កូនៗ រាល់រូបពិតមែន ប៉ុន្តែ ចិត្តគំនិត គឺថាគាត់មិនអាចបង្កើតឱ្យដូចពួកគាត់បានទាំងអស់នោះទេ។ ការទុកសេរីភាពឱ្យកូនចៅរើសគូស្រករមិនមែនជាការបដិសេធចោលនូវប្រពៃណីខ្មែរនោះទេ ប៉ុន្តែ វាគឺជាការផ្តល់សិទ្ធិសំរេចឱ្យបុគ្គលម្នាក់។ ការពិភាក្សាគ្នាឱ្យបានហ្មត់ចត់ជាមុនរវាងឪពុកម្តាយ និងកូនជាមធ្យោបាយមួយដ៏ប្រសើរបំផុតដើម្បីបញ្ចៀសឱ្យខានតែបាននូវដំបៅវិប្បដិសារីជាពិសេសអំពើហិង្សា ឬសោកនាដកម្មជាយថាហេតុណាមួយ។

គន្ធា និង ដារិដ

# សេរីភាពរើសគូស្រករ...

**បច្ចុប្បន្ននេះទំនោររើសគូស្រករដោយខ្លួនឯងរបស់យុវជនកាន់តែមានច្រើន។ ពួកគេចង់បានសេរីភាពក្នុងការជ្រើសរើសដោយខ្លួនឯង ជាជាងការរៀបចំទុកដាក់ដោយឪពុកម្តាយ។**

សព្វថ្ងៃនេះ គេអាចថាជាបដិវត្តន៍របស់យុវជនក៏ថាបាន ក្នុងការរើសគូអនាគតដោយខ្លួនឯង ផ្ទុយពីសម័យមុន ដែលមានឪពុកម្តាយជាអ្នកចុងផ្តើម។ លោក ស៊ិន សុធា ស្ថិតក្នុងចំណោមយុវជនមួយចំនួន ដែលបានប្រើប្រាស់សិទ្ធិសេរីភាពក្នុងការជ្រើសរើសប្រពន្ធខ្លួនឯង។ សុធាបានស្គាល់មិត្តស្រីម្នាក់ដែលរៀននៅវិទ្យាល័យជាមួយគ្នាក្នុងខេត្តពោធិ៍សាត់។ ក្រោយពីបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ សុធាបានសន្សំប្រាក់ដើម្បីសំរេចបំណង។ បន្ទាប់មក គាត់បានសំណូមពរឪពុកម្តាយគាត់ឱ្យចូលទៅស្តីឪពុកម្តាយខាងស្រី។ អាពាហ៍ពិពាហ៍របស់គូស្នេហ៍ទាំងពីរនាក់បានលេចចេញជារូបរាងពិតប្រាកដ ដោយសារតែប្រាក់សន្សំផ្ទាល់របស់សុធាប្រហែល ២០០០ ដុល្លារ។ លោក សុធា ពន្យល់ពីមូលហេតុនៃការសំរេចជ្រើសរើសដោយខ្លួនឯងថា ៖ "នេះជាសេរីភាពសំរាប់តំរូវការផ្ទាល់របស់យើង។ ចំពោះរឿងគូស្រករនេះ ឪពុកម្តាយមិនអាចរើសឱ្យត្រូវដូចចិត្តយើងបានឡើយ ពីព្រោះតែនេះជាអនាគតរបស់យើងផ្ទាល់"។ អាពាហ៍ពិពាហ៍របស់សុធាគឺជាគំរូមួយ សំរាប់យុវជនជំនាន់ថ្មីដែលយើងអាចចាត់ចូលទៅជាអាពាហ៍ពិពាហ៍ទំនើបមួយបាន។

ក្រៅអំពីទស្សនៈខាងលើ ការទទួលខុសត្រូវចំពោះជំរើសរបស់ខ្លួនក៏ត្រូវបានយល់ថាមានសារៈសំខាន់ផងដែរ។ ការស្គាល់គ្នាច្បាស់មុននឹងរៀបការជាការល្អប្រសើរម្យ៉ាងដែរ ដើម្បីចៀសវាងនូវជម្លោះ និងហិង្សាក្នុងគ្រួសារ ជាពិសេសការលែងលះគ្នា។ លោក ខៀវ ចិត្រា បានឯកភាពទាំងស្រុងចំពោះមតិខាងលើនេះ។ លោកបានពន្យល់ថា៖ "ការជ្រើសរើសដោយខ្លួនឯងជាការផ្តល់ភាពទទួលខុសត្រូវមកឱ្យយើងសំរាប់ថ្ងៃក្រោយ ពីព្រោះជាការសំរេចរបស់យើង។ ម្យ៉ាងទៀត ខ្ញុំមិនចង់រំខានដល់ឪពុកម្តាយឱ្យរវល់តែរឿងដើររកប្រពន្ធឱ្យ"។ សំរាប់ ចិត្រា ការស្ម័គ្រចិត្តរើសគូស្រករដោយខ្លួនឯងមានលក្ខណៈងាយស្រួល ព្រោះពេលវេលាចូលស្តីដណ្តឹង ឬរៀបការ គឺសាមីខ្លួនជាអ្នកកំណត់ដោយអាស្រ័យទៅលើធនធាននិងថវិកាដែលសន្សំបាន។ ដោយឡែក ចំពោះលោក ហៀង វិរៈ សេរីភាពក្នុងការរើសគូស្រករមិនមែនថា មិនគោរពឪពុកម្តាយទេ។ លោកបាននិយាយថា៖ "ការរើសគូស្រករចិត្តឯងមិនមែនជាការក្បត់ឧត្តមគតិ ចំពោះការគោរពឪពុកម្តាយនោះឡើយ។ យើងគ្រាន់តែសំណូមពរនូវអ្វីដែលយើងពេញចិត្ត និងឱ្យពួកគាត់ជាអ្នកដឹងឮក្នុងនាមជាអ្នកមានគុណ"។ ជាទូទៅ ពេលរើសគូស្រករ ឪពុកម្តាយតែងមើលពូជពង្ស ឬទ្រព្យសម្បត្តិខាងស្រី។ ទាំងនេះគឺផ្ទុយស្រឡះពីចិត្តយុវជនដែលចង់ស្គាល់គ្នាច្បាស់ជាមុនសិន មុននឹងរៀបការ។

ដារិដ និងគន្ធា



គូស្រករដែលបានប្រើប្រាស់សិទ្ធិសេរីភាពរបស់ខ្លួន

# ជួសជុលម៉ូតូ

**ការវិវត្តន៍នៃសេដ្ឋកិច្ចជាតិបានធ្វើឱ្យការប្រើប្រាស់ម៉ូតូធ្វើជាមធ្យោបាយធ្វើដំណើរនិងដឹកជញ្ជូនរបស់ប្រ-ជាជនខ្មែរកើនឡើងពុំចេះឈប់ឈរដែលធ្វើឱ្យមុខរបរជួសជុលម៉ូតូមានការរីកសាយគ្រប់ទីកន្លែង។**



Photo: P. Samphy

សកម្មភាពរបស់យុវសិស្សដែលកំពុងរៀនជួសជុលម៉ូតូនៅសាលាបច្ចេកទេសខ្មែរដៃដែក

ប្រសិនបើយានជំនិះរបស់យើងមានបញ្ហា ឬខូច យើងអាចទៅរកជាងឱ្យមកធ្វើការជួសជុល។

ចំពោះជាងម៉ូតូ គេទាំងនោះជំនាញយ៉ាងខ្លាំងលើផ្នែកបច្ចេកទេសត្រួតពិនិត្យ និងស្គាល់គ្មានចន្លោះនូវគ្រឿងបន្លាស់ម៉ូតូ។ នៅពេលមានគ្រឿងមួយណាខូច គេអាចដឹងភ្លាមថាគ្រឿងនោះអាចជួសជុលប្រើប្រាស់វិញបាន ឬក៏ត្រូវធ្វើការផ្លាស់ប្តូរថ្មី។ កិច្ចការរបស់ពួកគេមានច្រើន មានជាអាទិ៍ ដូរប្រេងម៉ាស៊ីន ដូរស្បែកហ្វ្រាំង ដូរច្រវ៉ាក់ លាងបេនសាំង និងមើលប្រព័ន្ធភ្លើង។ល។ និង។ល។ ការងារទាំងនេះទាមទារឱ្យពួកគេមានចំណង់ចំនូលចិត្ត ពីព្រោះជួនកាលពួកគេត្រូវប្រឡាក់ប្រឡូកទៅដោយប្រេងម៉ាស៊ីនពេញមួយថ្ងៃ។ តាមប្រសាសន៍របស់លោក លី សេងហាក់ ជាជាងដែលមានបទពិសោធន៍លើការងារជួសជុលម៉ូតូជិត៨ឆ្នាំ នៅក្រុងតាខ្មៅ បានឱ្យដឹងថា ចំពោះការងារជួសជុលម៉ូតូនេះ យើងត្រូវមានចរិតទន់ភ្លន់ និងមិនត្រូវឆេវឆាវ។ ប្រសិនបើអតិថិជនគេឱ្យធ្វើអ្វីគឺយើងត្រូវធ្វើតាមគេ។ យើងត្រូវតែយកចិត្តទុកដាក់ឱ្យបានខ្ពស់ ផ្ចិតផ្ចង់ និងត្រូវប្រុងប្រយ័ត្ន ដោយរាល់ពេលធ្វើហើយម្តងៗ យើងត្រូវធ្វើតេស្តិ៍សាកល្បងម៉ូតូឡើងវិញដើម្បីធានាឱ្យបានដឹងថា ការជួសជុលនោះគឺមានប្រសិទ្ធិភាព។

ជាទូទៅ ចំនូលដែលបានមកពីការជួសជុលនេះបានច្រើន ឬតិចគឺអាស្រ័យទៅលើទំហំនៃការជួសជុលនោះផងដែរ មានន័យថា ជួសជុលច្រើនយើងទទួលបានលុយច្រើន។ តួយ៉ាងដូចជា ការរឹតច្រវ៉ាក់បន្តិចបន្តួច យើងទទួលបានប្រាក់៥០០រៀល។ បើយើងរើម៉ាស៊ីនដូរគ្រឿង យើងអាចទទួលបានប្រាក់ឈ្នួលពី១៥០០០ ទៅ២០០០០រៀល។

ចំណែក លោក យ៉ង ផានី ប្រធានបច្ចេកទេសនៃសាលាខ្មែរដៃដែករាជធានីភ្នំពេញបានពន្យល់ថា ជួសជុលម៉ូតូគឺជាមុខជំនាញមួយដែលរៀនឆាប់ចេះ។ ហើយពេលអនាគត មុខរបរជួសជុលម៉ូតូនឹងរឹតតែរីកចំរើនឡើងថែមទៀត ពីព្រោះការប្រើប្រាស់ម៉ូតូនៅតែរីកសុះសាយពាសពេញប្រទេស។ តាមធម្មតាដើម្បីចេះជួសជុលម៉ូតូ យើងអាចរៀនសូត្រតាមជាងចាស់ៗដែលមានបទពិសោធន៍ ឬមួយក៏ទៅរៀននៅតាមសាលាបច្ចេកទេសផ្សេងៗទៀតក៏បានដែរ។

ផាត សំភី

## សាលាផ្សេងៗបង្រៀនធ្វើម៉ូតូ

សាលាបច្ចេកទេសខ្មែរដៃដែក: ថ្លៃសិក្សា១២០ដុល្លារ។ រយៈពេលពី៣ខែ ទៅ ៥ខែ។ ទាក់ទងតាមទូរស័ព្ទ: ០១២ ៨៩៨ ៥៧៤ ឬ០១២ ៨៥១ ៦១៧។

សាលាវិមានទិព្វ: តំលៃសិក្សា១០០ដុល្លារ រយៈពេលពី៣ខែ ទៅ ៤ខែ ទាក់ទងតាមទូរស័ព្ទ: ០១២ ៦៣៧ ០៥៩។

មជ្ឈមណ្ឌលបណ្តុះបណ្តាលជនពិការបន្ទាយព្រាប: សំរាប់តែជនពិការ រយៈពេល១ឆ្នាំ។ ទាក់ទងតាមទូរស័ព្ទ: ០១២ ៨៣១ ២៥២។

# សុខភាព

## តើគ្រុនឈាមជាអ្វី?



Photo: Fr. Omer

លោកស្រី Marissa REGENO-MANAMPAN វេជ្ជបណ្ឌិត ជំងឺកុមារ នៃគ្លីនិកសហគមន៍ និង គ្រួសារពេទ្យ

លោកស្រីវេជ្ជបណ្ឌិតមានប្រសាសន៍ថា គ្រុនឈាមគឺជាជំងឺដែលឆ្លងពីម្នាក់ទៅម្នាក់តាមរយៈមូសខាំ។ មូសនោះមានឈ្មោះតាមភាសាបច្ចេកទេសថា Aedes aegyptii។

ជាទូទៅ ជំងឺនេះបញ្ចេញរោគសញ្ញាដោយសម្តែងចេញតាមរយៈអាការៈគ្រុនក្តៅខ្លាំង មានការឈឺក្បាល និងឈឺចាប់រាងកាយ។ល។ ដើម្បីធ្វើការព្យាបាល អ្នកជំងឺចាំបាច់ត្រូវតែទៅឱ្យវេជ្ជបណ្ឌិតពិនិត្យអាការៈរោគ។ អ្នកជំងឺអាចទទួលទានថ្នាំបំបាត់ការឈឺចាប់ Paracetamol ហើយនិងផឹកទឹកទទួលទានអាហារ និងសំរាកឱ្យបានច្រើន ប៉ុន្តែ មិនត្រូវប្រើប្រាស់ថ្នាំ Aspirine ឡើយ ពីព្រោះ នឹងមានគ្រោះថ្នាក់ដោយការហូរឈាមតាមច្រមុះ។ បើមានការព្យាបាលទាន់ពេលវេលា និងត្រឹមត្រូវ ជំងឺនេះគឺអាចជានៅក្នុងរយៈពេល២សប្តាហ៍។ ប៉ុន្តែ បើជំងឺគ្រុនឈាមឈានចូលដល់ដំណាក់កាលនៃការបញ្ចូលឈាមហើយនោះ គ្រោះថ្នាក់ធ្ងន់ធ្ងរនឹងកើតមានដែលអាចនាំទៅរកសេចក្តីស្លាប់បាន។ ដើម្បីបង្ការជំងឺគ្រុនឈាម យើងត្រូវសំអាតជុំវិញគេហដ្ឋានរបស់យើងឱ្យបានស្អាតដោយកុំឱ្យមានអ្វីៗ ដែលអាចធ្វើឱ្យទឹកដក់បាន។ ជាទូទៅ ជំងឺនេះមានឆ្លងចំពោះគ្រប់វ័យទាំងអស់។

ផាត សំភី និង ហ៊ូ សុខធារី

# CROAP: មណ្ឌលកសិដ្ឋានថ្មី

**ជាមណ្ឌលកសិដ្ឋានតែមួយគត់របស់ព្រះសហគមន៍កាតូលិកស្ថិតនៅក្នុងភូមិកែវមុនី ប្រមាណ៨គីឡូម៉ែត្រ មុនទៅដល់ទីរួមខេត្តពោធិ៍សាត់ នៃភូមិភាគបាត់ដំបង ដែលមានផ្ទៃដីប្រមាណជាង៦ហិចតា។**



Photo: Fr. Omer

លោកឪពុក ហែរ ណាន់
ប្រធានគ្រប់គ្រងមណ្ឌលកសិដ្ឋាន-គ្រាប់

បន្ទាប់ពីធ្វើដំណើរតាមផ្លូវលំក្រាលក្រួសក្រហម ចុះពីលើផ្លូវជាតិអស់រយៈពេលប្រមាណជា ៥នាទី រួចមក យើងបានមកដល់ដីភូមិមួយដែលមានរបងខ្សែលួសព័ទ្ធជុំវិញ ហើយមានផ្លាកតូចមួយសរសេរអក្សរខ្មែរថា "សូមស្វាគមន៏ មណ្ឌលកសិដ្ឋាន-គ្រាប់"ដែលស្ថិតនៅខាងស្តាំដៃរបស់យើង។ ពេលយើងចូលទៅខាងក្នុងកសិដ្ឋាន យើងពុំបានស្តាប់ឮសំលេងអ្វីអរដូចនៅលើដងផ្លូវឡើយ។ ពេលនេះយើងឮសូរតែសំលេងបក្សាបក្សីយ៉ាងខ្សៀវខ្សារ នៅតាមគម្លោតព្រៃជាទ្រនំរបស់ខ្លួន ដោយសារតែព្រះសូរិយាហៀបអស្តង្គតទៅហើយនោះជាពិសេសសំលេងសត្វមាន់ ទា ក្ងាន ដែលមាននៅក្នុងរោងឈើប្រក់ស្បូវរបស់កសិដ្ឋាននេះ ។

ចំណែកផ្នែកខាងមុខជាប់នឹងរបង យើងសង្កេតឃើញមានថ្នាលពីរអមសងខាងផ្លូវចូល មានបន្សល់នូវកព្រាំងស្រូវដែលទើបប្រមូលផលហើយថ្មីៗ។ នៅក្នុងថ្នាលនេះមានដុបដីលើកខ្ពស់ៗ កំពស់ប្រហែលជាកន្លះម៉ែត្រ លើដុបទាំងនេះមានដាំកូនស្វាយទាំងអស់។ លោកគ្រូពិសិដ្ឋអ្នកថែទាំដំណាំទាំងនោះមានប្រសាសន៏ថា "ដើមស្វាយទាំងនេះបានដាំតាំងពីរដូវវស្សាមុនស្ទូងស្រូវក្នុងថ្នាលនេះមកម្ល៉េះ។ សព្វថ្ងៃនេះជារដូវក្តៅ វារាងស្រពោនបន្តិច តែបើស្រោចទឹកបានច្រើនវានឹងល្អ ហើយមានលាស់ស្លឹកច្រើន"។

លោកឪពុក ហែរណាន់ ជាប្រធានគ្រប់គ្រងកសិដ្ឋាននេះបានមានប្រសាសន៏ថា "ដោយសារបងប្អូននៅក្នុងភូមិជិតនេះភាគច្រើនទើបតែត្រលប់មកភូមិដ្ឋានរបស់ខ្លួនវិញ នៅអំឡុងឆ្នាំ១៩៩៣។ គេក៏បានចាប់ផ្តើមប្រកបរបរកសិកម្មឡើងវិញ ប៉ុន្តែ ពុំមានប្រភពទឹកគ្រប់គ្រាន់ដើម្បីប្រកបរបរនេះឱ្យបានប្រសើរឡើយ។ ដូច្នេះ បញ្ហាដែលនៅចំពោះមុខរបស់យើងគឺធ្វើយ៉ាងណាដើម្បីមានប្រភពទឹកច្រើន ដោយធ្វើការជីកស្រះជាប់ប្រឡាយទឹកដែលមាន ដើម្បីស្តុកទឹកសំរាប់រដូវដែលខ្វះទឹក។ ជាក់ស្តែង ក្នុងកសិដ្ឋាន មានស្រះស្តុកទឹកជាច្រើនកន្លែង"។ លោកឪពុកបានលើកពាក្យស្លោកមួយឃ្លាថា "ដើម្បីឱ្យមនុស្សបានហូបត្រី យើងមិនឱ្យត្រីគេហូបទេ គឺត្រូវបង្រៀនឱ្យគេចេះរកត្រីវិញ" ទើបគេអាចហូបត្រីបានយូរ។ កន្លងមកព្រះសហគមន៏ មានបទពិសោធន៏មួយគឺនៅពេលដែលប្រជាជនអស់ស្បៀងអាហារ គឺយើងតែងតែចែកស្បៀងឱ្យទៅគេ។ នេះមិនមែនជាវិធីដោះស្រាយបានយូរអង្វែងឡើយព្រោះនៅពេលក្រោយគេនឹងអត់ទៀត។ ដូច្នេះហើយទើបលោកឪពុកមានគំនិតផ្តួចផ្តើមកសាងជាកសិដ្ឋាននេះឡើង ក្នុងន័យមួយ ដើម្បីផ្សារភ្ជាប់ជាមួយនឹងបងប្អូនក្នុងសហគមន៏នៅតាមជនបទ។ នៅក្នុងកសិដ្ឋានមានចិញ្ចឹមមាន់មេ មាន់យកពង មាន់បារាំង ទា ក្ងាន ជ្រូក ដាំបន្លែ និងមានដំណាំផល្លានុផលជាច្រើនមុខទៀត។ ទាំងនេះមិនមែនជាប្រយោជន៏សំរាប់តែមណ្ឌលប៉ុណ្ណោះទេ គឺជាប្រយោជន៏ដល់បងប្អូនក្នុងភូមិជិតខាង ក្នុងការមកស្វែងយល់នូវបច្ចេកទេសកសិកម្មព្រមទាំងអនុវត្តន៏ផ្ទាល់ផងដែរ។ ក្នុងនេះមណ្ឌលកំពុងកាប់រៀនព្រៃធ្វើថ្នាលសំរាប់ដំណាំស្រូវបន្ថែមលើថ្នាលដែលមានហើយ។ ស្របជាមួយគ្នានេះ មណ្ឌលក៏មិនភ្លេចពីការការពារព្រៃឈើដែរ គឺបានរក្សាដើមឈើណាដែលមានប្រយោជន៏ទុកដើម្បីរួមចំណែកក្នុងការរក្សាបរិស្ថានដែរ។ នៅក្នុងកសិដ្ឋានមានសង់ផ្ទះជាច្រើន សំរាប់ធ្វើសិក្ខាសាលា និងដើម្បីទទួលភ្ញៀវមកសំណាក់ធម៌ផងដែរ។

សុវណ្ណា

## គោលបំណងមណ្ឌលកសិដ្ឋាន

ជួយក្មេង-យុវជនក្នុងភូមិជិតខាងទទួលការអប់រំពីបច្ចេកទេសកសិកម្ម ដោយអនុវត្តផ្ទាល់ក្នុងមណ្ឌល និងនៅផ្ទះមាន: បច្ចេកទេសដំណាំស្រូវ ដាំបន្លែ ដំណាំផ្សេងៗ។ ការចិញ្ចឹមត្រី ជ្រូក ដោយធ្វើទ្រុងជ្រូកនៅលើស្រះចិញ្ចឹមត្រី។ ការប្រើប្រាស់និងផលិតទឹកស្អាត-ជីកអណ្តូងទឹក។ មណ្ឌលក៏បានជួយសាលាកែវមុនីដែលនៅជិតនោះ ដោយអប់រំពីកសិកម្ម សិល្បៈ និងឧបត្ថម្ភគ្រូឱ្យបង្កើតសាលាមត្តេយ្យ។

# សង្គមស៊ីវិល និងគ្រោះរាំងស្ងួត

នៅប្រទេសកម្ពុជា វិស័យកសិកម្មមានតួនាទីយ៉ាងសំខាន់សំរាប់ទ្រទ្រង់សន្តិសុខស្បៀង និងសេដ្ឋកិច្ចជាតិ។ នៅរដូវវស្សាឆ្នាំ២០០៤នេះ គ្រោះរាំងស្ងួតបានកើតឡើងស្ទើរតែទូទាំងប្រទេសដែលធ្វើឱ្យដំណាំស្រូវរងការខូចខាតអស់ជាច្រើន។

កសិកម្មរបស់ប្រទេសកម្ពុជាយើង មានលក្ខណៈជាកសិកម្មយថាផល ដោយសារតែយើងពឹងផ្អែកទៅលើកត្តាអំណោយផលនៃធម្មជាតិ។ នេះមានន័យថា យើងនឹងជួបប្រទះនូវផលវិបាកជាច្រើននៅពេលមានគ្រោះមហន្តរាយរាំងស្ងួត ឬគ្រោះធម្មជាតិផ្សេងៗដែលកើតមានឡើង ប្រសិនបើគ្មានការដោះស្រាយឱ្យបានសមស្របទេនោះ។ អង្គការអន្តរជាតិ ដូចជា អង្គការស្បៀងអាហារពិភពលោក WFP អង្គការ Oxfam និងបណ្ដាអង្គការដទៃផ្សេងៗទៀត ដែលកំពុងតែបំពេញបេសកកម្មនានា ទាក់ទងទៅនឹងវិស័យកសិកម្មនៅកម្ពុជាបានសម្ដែងនូវក្ដីបារម្ភរបស់ខ្លួនចំពោះគ្រោះទុរ្ភិក្សដែលអាចនឹងកើតមានឡើងជាយ-ថាហេតុនៅឆ្នាំ២០០៥ខាងមុខនេះ។

ក្នុងនោះ លោក យ៉ង សាំងកុមារ នាយកមជ្ឈ-មណ្ឌលសិក្សា និងអភិវឌ្ឍកសិកម្មកម្ពុជានៃអង្គការក្រៅរដ្ឋាភិបាលមួយក៏បានផ្ដល់ជាអនុសាសន៍ដើម្បីស្វែងរកយុទ្ធសាស្ត្រ ឬដំណោះស្រាយនានាសំរាប់កសិកម្មនៅកម្ពុជាដែលកំពុងតែប្រឈមមុខនឹងបញ្ហានាពេលបច្ចុប្បន្ន និងក៏ដូចជាទៅថ្ងៃអនាគតដែលមានខ្លឹមសារដូចខាងក្រោម:

១. ត្រូវរៀបចំប្រព័ន្ធស្ដុកទឹកនៅវាលស្រែតាមរយៈការជីកប្រឡាយតូចៗ ឬក៏ស្រះដែលយើងហៅថាស្រែពហុប្រយោជន៍។ ប្រព័ន្ធនេះវាមានលក្ខណៈល្អត្រង់ថាយើងអាចបង្ហូរទឹកចេញពីស្រែពេលមានទឹកច្រើន ហើយអាចស្រោចស្រពវិញនៅពេលដែលស្រែខ្វះទឹក។

២. ត្រូវបង្កើតឱ្យមានអាង ឬស្រះស្ដុកទឹកនៅតាមភូមិដែលអាងទឹកនេះ អាចប្រើធ្វើជាកន្លែងអភិរក្សត្រី និងដាក់ទឹកសំរាប់មនុស្សប្រើប្រាស់ទូទៅ សំរាប់សត្វពាហនៈ និងសំរាប់ស្រោចស្រពបន្លែ។ នៅភូមិនីមួយៗ គេគួរសម្របសម្រួលគ្នាដើម្បីបង្កើតឱ្យមានអាង ឬស្រះរួមគ្នា គឺយ៉ាងតិចណាស់ក៏ត្រូវឱ្យមានចំនួនមួយដែរ។

៣. ត្រូវសហការគ្នាដើម្បីស្ដារប្រឡាយដែលមានស្រាប់ ហើយធ្វើជាទ្វារទឹកដើម្បីតម្កល់ និងទប់កុំឱ្យទឹកហូរចេញទាំងអស់ពេក។

៤. ត្រូវបង្កើននូវការស្ដុកទឹកភ្លៀង តាមគ្រួសារដូចជាតាមរយៈត្រពាំង ឬស្រះនៅជុំវិញផ្ទះ។

៥. ដាំដើមឈើឱ្យបានច្រើនដើម្បីបង្កើនការហូរទឹកចូលក្រោមដី (តាមរយៈឫសឈើ) និងបង្កើនកម្ពស់ទឹកដែលមាននៅក្រោមដី។

៦. ត្រូវប្រើប្រាស់ជីធម្មជាតិឱ្យបានច្រើនដើម្បីជួយឱ្យមានការស្រូប និងរក្សាសំណើមបានយូរ។

៧. ប្រសិនបើអាចធ្វើបាន គួរគិតគូរប្រើប្រាស់នូវបច្ចេកទេសស្រោចស្រព តាមបែបផែនជាតំណក់ទឹកភ្លៀង។ ហើយការស្រោចស្រពនេះគួរតែធ្វើនៅពេលល្ងាច ដោយចៀសវាងនូវការបង្ហូរទឹកដាក់ពេញៗស្រែ ដែលនាំឱ្យទឹកបាត់បង់អស់ច្រើនដោយសារតែរំហួតនោះ។

៨. ត្រូវដាំដំណាំស្បៀងបម្រុង ឬស្បៀងបន្ទាប់បន្សំដូចជាដំឡូង (ដំឡូងមី ដំឡូងជ្វា ដំឡូងដៃខ្លា) បន្លែ ពោត ល្ង សណ្ដែក ។ល។ និង។ល។

លោក យ៉ង សាំងកុមារបានមានប្រសាសន៍ថា: "ជាធម្មតា កសិករខ្មែរយើងតែងតែមានគំនិតច្នៃប្រឌិតខ្ពស់ និងមានការតស៊ូក្នុងការដោះស្រាយបញ្ហាផ្សេងៗស្រាប់ហើយ។ ប៉ុន្តែនេះនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ យើងត្រូវនាំគ្នាបង្កើននូវគំនិតនៃការច្នៃប្រឌិតបច្ចេកទេស និងធ្វើការសហការគ្នាទៅវិញទៅមកឱ្យកាន់តែខ្លាំងក្លាថែមទៀតដោយចៀសវាង និងកុំបណ្ដែតបណ្ដោយ



Photo: L. Sovanna

ដីប្រេះក្រហែងក្នុងស្រែប្រជាពលរដ្ឋឃុំ ត្រាំពង្រ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល

### ព័ត៌មានពីអង្គការ FAO

អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ FAO បានប្រកាសថា ប្រទេសនានានៅលើពិភពលោកនឹងមានលំនឹងលើទិន្នផលស្រូវ ឬកើនឡើង រីឯប្រទេសកម្ពុជាទិន្នផលស្រូវនឹងមានការធ្លាក់ចុះ។

ក្រសួងកសិកម្មកម្ពុជាបានទទួលស្គាល់សេចក្តីប្រកាសនេះ ហើយប៉ាន់ប្រមាណថា ការប្រមូលផលស្រូវឆ្នាំ២០០៤នេះអាចធ្លាក់ចុះទាបជាងកាលពីឆ្នាំទៅ ប្រមាណពី ៧០០ពាន់តោន ទៅ៨០០ពាន់តោន បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៣ កម្ពុជាបង្កើនផលស្រូវលើផ្ទៃដីជាង២លានហិចតាដោយប្រមូលផលដំបូងបាន៤,៣លានតោន ដែលអាចសល់ពីតំរូវការ៦០០ពាន់តោន។

អង្គការ FAO បានប៉ាន់ប្រមាណថា ឆ្នាំនេះ ពិភពលោកទាំងមូលនឹងផលិតស្រូវបាន៦១១លានតោន គឺកើន២៧លានតោនលើសឆ្នាំ២០០៣។ ប្រទេសដែលផលិតបានច្រើនជាងគេគឺ ប្រទេសចិន ឥណ្ឌូនេស៊ី ជប៉ុន កូរ៉េ និងនៅអាហ្វ្រិកមាន អេហ្ស៊ីប និងម៉ាដាហ្គាស្កា។

ខ្លួនដោយអាស្រ័យតែលើជំនួយពីខាងក្រៅ"។ មានព្រះរាជបន្ទូលទៅកាន់ប្រជានុរាស្ត្រនៅខេត្តសៀមរាប ព្រះករុណាព្រះបាទនរោត្តមព្រះបរមនាថសីហមុនី បានធ្វើការអំពាវនាវឱ្យជនរួមជាតិរបស់ព្រះអង្គ ខិតខំបង្កើនការដាំដំណាំបន្ទាប់បន្សំផ្សេងៗថែមទៀតឱ្យបានច្រើនដើម្បីសំរាលគ្រោះទុរ្ភិក្ស ដែលអាចនឹងកើតមាន បណ្តាលមកពីភាពរាំងស្ងួតនៅក្នុងឆ្នាំ២០០៤នេះ។ គួររំលឹកផងដែរថា ព្រះអង្គធ្លាប់មានព្រះរាជបន្ទូលសន្យានៅមុខប្រជារាស្ត្រថា ព្រះអង្គនឹងបំពេញព្រះរាជកាតព្វកិច្ចខាងសង្គមកិច្ច និងមនុស្សធម៌ឱ្យបានខ្លាំងក្លាជាមួយសង្គមស៊ីវិលនានានៅក្នុងប្រទេសកម្ពុជា។

អត្ថបទរាយការណ៍ដោយ សំ វ៉ានី



Photo: L. Sovanna

សម្តេច ហ៊ុន សែន មានប្រសាសន៍ថា រាជរដ្ឋាភិបាលអាណត្តិនេះ គឺជារាជរដ្ឋាភិបាលធារាសាស្ត្រ

# នយោបាយកសិកម្មថ្មី

**ចំពោះវិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ រាជរដ្ឋាភិបាលអាណត្តិទីបីបាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។**

ក្នុងអាណត្តិទី៣នេះរាជរដ្ឋាភិបាលបាននឹងកំពុងយកចិត្តទុកដាក់ទៅលើគោលនយោបាយកាត់បន្ថយភាពក្រីក្រ តាមរយៈវិស័យស្នូលសំខាន់ៗរបស់សេដ្ឋកិច្ចជាតិ មានជាអាទិ៍វិស័យកសិកម្ម។ បញ្ហាចម្បងៗ ដែលជាកង្វល់ចំពោះវិស័យកសិកម្មដែលប្រទេសយើងកំពុងតែប្រឈមមុខនោះរួមមាន កំណើននៃសំពាធលើធនធានដីធ្លី និងការធ្វើសម្បទានដីកសិកម្ម ការកេងយកចំណេញពីការតំឡើងថ្លៃដីធ្លី និងកំណើននៃប្រជាពលរដ្ឋ។ លើសពីនេះ ក៏មានកំណើននៃការហូរចូលរបស់ផលិតផលកសិកម្មមកពីបណ្តាប្រទេសផ្សេងៗ។ ចំនួនយុវជននៅតាមជនបទកំពុងតែកើនឡើង ប៉ុន្តែ ជាទូទៅពួកគេមិនមានឱកាសបានរៀនសូត្រនូវជំនាញ និងវិជ្ជាជីវៈផ្សេងៗដែលទាក់ទងទៅនឹងវិស័យកសិកម្មនោះឡើយ។ ម្យ៉ាងវិញទៀត បញ្ហាគ្រោះធម្មជាតិផ្សេងៗ មានដូចជា ភាពរាំងស្ងួត ទឹកជំនន់ យើងមិនទាន់ដោះស្រាយបាន។ ចំនួនកសិករតូចតាចកាន់តែច្រើនឡើងៗ ជំពាក់បំណុលគេ ដោយការចំណាយលើការថែទាំសុខភាព និងចំណាយទៅលើវត្ថុធាតុដើមកសិកម្ម។ ទាក់ទិនទៅនឹងបញ្ហានេះ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងពី "យុទ្ធសាស្ត្រចតុកោណ" របស់រាជរដ្ឋាភិបាលថាៈ " រាជរដ្ឋាភិបាលនឹងបង្កើនការប្រើប្រាស់ធនធានក្នុងស្រុកដើម្បីអនុវត្តការធ្វើពហុវប្បកម្ម និងប្រពលវប្បកម្មកសិកម្មក្នុងគោលបំណងធានាឱ្យខានតែបាននូវនិរន្តរភាពនៃកំណើនសេដ្ឋកិច្ចជាតិ ព្រមទាំងបង្កើតការងារ និងបង្កើនប្រាក់ចំនូលនៅតាមទីជនបទ និងធានានូវសន្តិសុខស្បៀងសំរាប់ប្រជាជនទូទៅ ហើយធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងការនាំចេញកសិផល"។ សម្តេចបានបន្តទៀតថាៈ "រដ្ឋាភិបាលនឹងបន្តអភិវឌ្ឍប្រព័ន្ធស្រោចស្រពផ្ទៃដី និងការគ្រប់គ្រងធនធានទឹកដោយផ្តោតការយកចិត្តទុកដាក់លើការបង្កើនប្រសិទ្ធិភាពក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ និងការកាត់បន្ថយនូវភាពងាយរងគ្រោះដោយគ្រោះធម្មជាតិ ដោយសារតែការពឹងផ្អែកទាំងស្រុងលើល័ក្ខខ័ណ្ឌធម្មជាតិ។

នៅឆ្នាំ២០០៥នេះ រដ្ឋាភិបាលបានបង្កើនថវិកាជាតិថែមទៀតទៅឱ្យក្រសួងសំខាន់ៗបីដែលបំរើដល់វិស័យកសិកម្ម មានដូចជា ក្រសួងធនធានទឹកប្រាក់ចំនួន ៣,៤៨លានដុល្លារ ក្រសួងកសិកម្មទឹកប្រាក់មានចំនួន១២,៥លានដុល្លារ និងក្រសួងអភិវឌ្ឍន៍ជនបទចំនួន ៦,១៥លានដុល្លារ។

# អំពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ដែលជាសម័យនៃការកាន់អំណាចរបស់ខ្មែរក្រហម ប្រជាជនកម្ពុជាបានស្លាប់ ទទួលរងនូវការបង្អត់អាហារ ទារុណកម្ម និងត្រូវធ្វើការជាទម្ងន់ដោយគ្មានសិទ្ធិសេរីភាពឡើយ។ នៅពេលខាងមុខនេះសាលាជម្រះក្តីចំរុះមួយនឹងបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងនោះ។ ក្នុងលេខនេះ "អ្នកនាំសារ" នឹងបង្ហាញប្រិយមិត្តអំពីដំណើរប្រព្រឹត្តិទៅខ្លះៗ នៃសាលាក្តីនេះ។



Photo: D.R

គំនូរពង្រាងៈ ចៅក្រមកម្ពុជា៣រូប រួមជាមួយនិងចៅក្រមអន្តរជាតិ២រូប ធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងសាលាជំនុំជម្រះក្តីវិសាមញ្ញមួយ ដោយមានការចូលរួមពីអ្នកជំនាញការជាតិ និងអន្តរជាតិជាច្រើនរូបទៀត។

**តើអ្នកណាខ្លះនឹងត្រូវនាំមកដើម្បីធ្វើការកាត់ទោស?**

ក្នុងស្មារតីចង់បានយុត្តិធម៌ ការពិត និងការផ្សះផ្សាជាតិ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានឯកភាពគ្នាថា អង្គជំនុំជម្រះវិសាមញ្ញមួយ គប្បីកំរិតការកាត់ទោសចំពោះតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានរៀបចំផែនការ ឬចេញនូវបទបញ្ជា និងអ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរទាំងនេះ រួមមាន ប៉ុលពត អៀង សារី ខៀវ សំផន នួន ជា មាស មុត តាម៉ុក ឌុច។ល។

**ចំពោះប្រទេសដែលធ្លាប់បានគាំទ្រ ឬក៏ជាប់ពាក់ព័ន្ធជាមួយកម្ពុជាប្រជាធិបតេយ្យ ឬក៏បណ្តាប្រទេសដែលប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមនៅកម្ពុជាមុនឆ្នាំ១៩៧៥ តើប្រទេសទាំងនោះត្រូវឡើងតុលាការដែរឬអត់?**

មិនទេ។ អង្គជំនុំជម្រះវិសាមញ្ញកាត់សេចក្តីតែលើបុគ្គលណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម។ តុលាការមិនអាចកាត់សេចក្តីប្រទេស ឬអង្គការណាបានឡើយ។

**ចុះចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយមេដឹកនាំខ្មែរក្រហម ឬអ្នកដទៃទៀតក្រោយឆ្នាំ១៩៧៩?**

មិនទេ។ អំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញមានព្រំដែន។ តុលាការនេះអាចកាត់សេចក្តីតែឧក្រិដ្ឋកម្មណា ដែលបានប្រព្រឹត្តនៅកម្ពុជាក្នុងចន្លោះថ្ងៃ ទី១៧ មេសា ១៩៧៥ ដល់ថ្ងៃ ទី៦ មករា ១៩៧៩ តែប៉ុណ្ណោះ។

## បញ្ហាអន្តរជាតិ

# ជម្លោះអ៊ីស្រាអែល-ប៉ាលេស្ទីន

**តើ O.L.Pជាអ្វី ?**

គឺជាអង្គការតស៊ូជាតិប៉ាលេស្ទីន បង្កើតឡើងនៅឆ្នាំ១៩៦៤ ដោយក្រុមប្រឹក្សាជាតិប៉ាលេ-ស្ទីន រួបរួមគ្នានៅទីក្រុង Jérusalem ដែលមានសម្ព័ន្ធអារ៉ាប់ជាអ្នកឧបត្ថម្ភធនធាន។

ឆ្នាំ១៩៤៧ : អង្គការសហប្រជាជាតិអនុម័តលើផែនការបែងចែកប្រទេសប៉ាលេស្ទីន ហើយទីក្រុង Jérusalem ស្ថិតនៅក្រោមលក្ខន្តិកៈអន្តរជាតិ។

ឆ្នាំ១៩៤៨ : ការប្រកាសរដ្ឋអ៊ីស្រាអែល។ សង្គ្រាមលើកទីមួយរវាងប្រទេសអ៊ីស្រាអែល និងពិភពអារ៉ាប់។

ឆ្នាំ១៩៦៧ : សង្គ្រាម ៦ថ្ងៃ។ ប្រទេសអ៊ីស្រាអែលដណ្តើមយកបានទឹកដី Sinaï ខ្ពង់រាប Golan តំបន់ Cisjordanie Gaza និងទីក្រុង Jérusalem ប៉ែកបូព៌ា។

ឆ្នាំ១៩៧៣ : ការវាយលុករបស់កងទ័ពស៊ីរី និងអេហ្ស៊ីបច្បាំងដណ្តើមយកទឹកដីដែលគេកាន់កាប់មកវិញ។ សង្គ្រាម Kippour ចាប់ផ្តើម។

ឆ្នាំ១៩៧៨ : កិច្ចព្រមព្រៀងនៅ Camps David រវាងអេហ្ស៊ីប អ៊ីស្រាអែល និងសហរដ្ឋអាមេរិក គ្រោងរៀបចំឱ្យជនជាតិប៉ាលេស្ទីន ដែលរស់នៅលើទឹកដីដែលគេកាន់កាប់នូវស្វ័យភាពមួយដែលមានព្រំដែនកំនត់ និងការសងមកឱ្យអ៊ីស្រាអែលវិញនូវទឹកដី Sinaï និងខ្ពង់រាប Golan។

ឆ្នាំ១៩៨៧ : កំនកំណើតនៃសង្គ្រាម Intifada (សង្គ្រាមចោលដុំថ្ម)។ សភានិរទេសនៃ O.L.P ប្រកាសរដ្ឋប៉ាលេ-



**តើអង្គជំនុំជម្រះវិសាមញ្ញនេះ គឺជាផ្នែកមួយនៃប្រព័ន្ធតុលាការជាតិ ឬជាតុលាការអន្តរជាតិ?**

អង្គជំនុំជម្រះវិសាមញ្ញនេះ គឺជាផ្នែកមួយនៃប្រព័ន្ធតុលាការកម្ពុជា។ ទោះជាយ៉ាងនេះក្ដីតុលាការមានលក្ខណៈពិសេសជារបៀប“សាលាក្ដីចំរុះ”។ ម្យ៉ាងវិញទៀតនោះ ភាគច្រើននៃមន្ត្រីដែលបំរើការងារនៅក្នុងតុលាការនេះ គឺសុទ្ធសឹងជាបុគ្គលិកដែលជាជនជាតិកម្ពុជា។ នេះគឺជាតុលាការដែលរួមមានចៅក្រមមកពីកម្ពុជា ចៅក្រមអន្តរជាតិ ព្រះរាជអាជ្ញា និងមេធាវី ការពារកម្ពុជា ព្រមជាមួយនឹងព្រះរាជអាជ្ញា និងមេធាវីការពារអន្តរជាតិ។ ពួកគេទាំងអស់គ្នានេះនឹងប្រើប្រាស់ច្បាប់កម្ពុជាផង និងច្បាប់អន្តរជាតិផងដែរ។

**តើអង្គជំនុំជម្រះវិសាមញ្ញធ្វើការរបៀបដូចម្ដេច?**

តុលាការមានពីរកម្រិតឬថ្នាក់គឺ សាលាដំបូង និងតុលាការកំពូល។ នៅសាលាដំបូងមានចៅក្រមមាន ៥រូប គឺចៅក្រមកម្ពុជាមាន ៣រូប និងអន្តរជាតិ ២រូប។ តុលាការកំពូលមានចៅក្រម ៧រូប គឺចៅក្រមកម្ពុជា ៤រូប និងអន្តរជាតិ ៣រូប។ តាមច្បាប់កម្ពុជាសព្វថ្ងៃនេះក៏ដូចជានៅប្រទេសជាច្រើនទៀតដែរ គឺគ្មានគណៈវិនិច្ឆ័យ ឬគណៈទីប្រឹក្សាប្រជាជនទេ។ រាល់ការសំរេចចិត្តទាំងអស់គឺជារបស់អង្គចៅក្រម។

**តើការដាក់ឱ្យខ្មែរក្រហមទទួលខុសត្រូវចំពោះមុខច្បាប់នឹងអាចជួយកាត់បន្ថយបាននូវភាពក្រីក្រនិងអំពើអយុត្តិធម៌ដែលកំពុងប៉ះពាល់ចំពោះសង្គមជាតិកម្ពុជាបានដែរឬ?**

បាន! សារៈសំខាន់របស់តុលាការ មិនត្រឹមតែដោះស្រាយកំហុសពីអតីតកាលប៉ុណ្ណោះទេ។ ប៉ុន្តែ សូម្បីតែប្រព័ន្ធច្បាប់និងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក៏នឹងទទួលបាននូវផលប្រយោជន៍ពីតុលាការនេះដែរ។ ការជំនុំជម្រះក្ដីនេះនឹងផ្ដល់នូវឱកាសឱ្យកម្ពុជាធ្វើជាគំរូនៅលើឆាកជាតិ និងអន្តរជាតិ។ ការទទួលបានឱកាសទាំងនេះ រួមបញ្ចូលជាមួយលទ្ធភាពក្នុងការអប់រំប្រជាជនអំពីសិទ្ធិរបស់ខ្លួននៅក្នុងសាលាជំនុំជម្រះក្ដី ព្រមទាំងជួយផ្ដល់សម្លេងកាន់តែច្រើនដល់ប្រជាជននៅក្នុងជួររាជរដ្ឋាភិបាល និងជូនដល់ពួកគាត់នូវអ្វីដែលគាត់រង់ចាំអស់រយៈពេលជាយូរមកហើយ។ នោះគឺជាភាពយុត្តិធម៌និងប្រព័ន្ធច្បាប់មួយដែលបំរើដល់តំរូវការរបស់គាត់។

សម្រង់ពីសៀវភៅ “ស្វែងយល់អំពីសាលាជម្រះក្ដីខ្មែរក្រហម” និងកាសែតរស្មីកម្ពុជា! សំ វ៉ានី

## កាលប្រវត្តិនៃតុលាការជម្រះក្ដីខ្មែរក្រហម

ឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានសុំឱ្យអង្គការសហប្រជាជាតិឧបត្ថម្ភបង្កើតសាលាក្ដីកាត់ទោសខ្មែរក្រហម។

ឆ្នាំ២០០១ រដ្ឋសភាជាតិអនុម័តច្បាប់បង្កើតតុលាការកាត់ទោស។

ខែមិថុនា ឆ្នាំ២០០៣ កិច្ចព្រមព្រៀងមួយ ជាមួយនឹងអង្គការសហប្រជាជាតិចែងថា“តើអន្តរជាតិឧបត្ថម្ភ និងសហការរបៀបណានៅក្នុងតុលាការនេះ?”។

ខែតុលា ឆ្នាំ២០០៤ សភាជាតិអនុម័តកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិអំពីច្បាប់នៃរឿងក្ដីក្ដាំរបស់មេដឹកនាំខ្មែរក្រហម។

ស្ទីនឯករាជ្យមួយ។ O.L.P បានទទួលស្គាល់នូវរដ្ឋអ៊ីស្រាអែលដោយមិនផ្លូវការ។

**ឆ្នាំ១៩៩៣ :** កិច្ចព្រមព្រៀងទីក្រុងអូស្លូ។ សន្ធិសញ្ញាគ្រោងរៀបចំការដកថយរបស់ជនជាតិអ៊ីស្រាអែលពីតំបន់ Gaza និងតំបន់ Jéricho និងការសម្រេចលើបញ្ហានៃជនជាតិប៉ាលេស្ទីន បន្ទាប់ពីរយៈពេល៥ឆ្នាំនៃស្វ័យភាព។

**ឆ្នាំ១៩៩៦ :** នយោបាយនៃការតាំងអាណានិគមជនជាតិជ្វីហ្វចាប់កើតមានឡើងសាជាថ្មី។

**ឆ្នាំ២០០០ :** លោក Ariel Sharon ធ្វើដំណើរទៅកាន់ទីលាននៃព្រះវិហារឥស្លាមនានានៅទីក្រុង Jérusalem។ ការចាប់ផ្ដើមនៃសង្គ្រាម Intifada លើកទី២។

**ឆ្នាំ២០០៣ :** “សន្លឹកនាំផ្លូវ” (la feuille de route) ដែលក្នុងនោះគ្រោងរៀបចំពីពេលនេះទៅដល់ឆ្នាំ២០០៥ ក្នុងការបង្កើតរដ្ឋពីរដែលស្ថិតនៅដាច់ដោយឡែកៗពីគ្នាត្រូវបានចេញផ្សាយប្រកាសជាសាធារណៈ។

**ការដកថយពីទឹកដី**

លោក Ariel Sharon អះអាងថា:“ ខ្ញុំបានសំរេចចិត្តយ៉ាងច្បាស់ថាដើរឱ្យរហូតដល់ទីបំផុតសំរាប់ការបែងចែកនេះ”។ បន្ទាប់ពីរយៈពេល ៣៧ឆ្នាំ នៃការកាន់កាប់ សភារដ្ឋហេប្រឺបានអនុម័តកាលពីចុងខែតុលា ឆ្នាំ២០០៤ នូវជំហានទីមួយនៃផែនការដកថយចេញពីទឹកដី Gaza។

P.R



# សម្រួលព្រះគម្ពីរឱ្យបានប្រសើរ

**សមាគមព្រះគម្ពីរបានចាត់ចែងការកែសម្រួលឡើងវិញនូវព្រះគម្ពីរដែលបានបកប្រែរួចហើយ ដើម្បីឱ្យគ្រិស្តបរិស័ទទាំងអស់ងាយស្រួលប្រើប្រាស់។**





Photos: L. Sovanna

លោកបូជាចារ្យ ប៉ុង ស្វ៊ីនិងលោកអារុណ កំពុងពិនិត្យព្រះគម្ពីរ

ព្រះគម្ពីរសំរាប់គ្រិស្តបរិស័ទត្រូវចាប់ផ្តើមធ្វើការកែសំរួលកាលពីថ្ងៃ ទី១៧ ១៨ និង ១៩ វិច្ឆិកា ២០០៤ ក្រោមការចាត់ចែងរបស់សមាគមព្រះគម្ពីរ ដែលជាអង្គការមួយរួមផ្សំដោយគ្រិស្តបរិស័ទទាំងអស់ គ្រប់និកាយ មានទាំងខាងកាតូលិក និងក្រុមជំនុំ។ គណៈកម្មការមួយដែលមានសមាជិក ២ រូប គឺលោកហ្វ្រង់ស័រ ប៉ុងស្វ៊ី និងលោកគ្រូគង្វាល សុខ ញឹមអារុណជាអ្នកប្រតិបត្តិកិច្ចការនេះ។ តាមប្រសាសន៏របស់លោក បូជាចារ្យ ប៉ុង ស្វ៊ី បានឱ្យដឹងថា : "ការងារនៃការកែសម្រួលព្រះគម្ពីរនេះមិនមែនងាយធ្វើឆាប់ហើយទេ យើងត្រូវការពេលវេលាយូរ គឺយ៉ាងតិចក៏៥ឆ្នាំដែរ។ នៅពេលនេះ យើងកំពុងធ្វើការកែសម្រួលលើគម្ពីរ សម្ព័ន្ធមេត្រីថ្មី ដែលត្រូវបានបកប្រែចប់រួចរាល់នៅរវាងឆ្នាំ ១៩៩៨"។ ជាទូទៅ ក្រោយពីការបកប្រែរួចរាល់ហើយម្តងៗ កំហុសឆ្គងតែងមានមិនលែងឡើយ ចំពោះខ្លឹមសារនៃព្រះគម្ពីរ។ តួយ៉ាង ការបកប្រែលើពាក្យពេចន៏មួយចំនួនអាចមិនសូវចំតាមអត្ថន៏យដែលចេញពីភាសាដើម គឺភាសាក្រិក ឬភាសាហេប្រឺ។ កន្លែងខ្លះអាចមានការភ្លេចភ្លាំងក្នុងការបកប្រែ។ ពាក្យខ្លះមានសភាពបុរាណពេក។ ម្យ៉ាងវិញទៀត ក៏អាចមានករណីដែលថា ក្នុងភាសាដើមគេប្រើពាក្យតែមួយ តែដល់ពេលបកមកជាភាសាខ្មែរ អាចមានប្រើរហូតដល់ទៅ២ ឬ ៣ពាក្យ ខុសគ្នាក៏មាន។

លោកគ្រូ សុខ ញឹមអារុណរៀបរាប់ឱ្យដឹងថា:" យើងចង់កែសម្រួលឱ្យល្អប្រសើរឡើងវិញនូវភាពឆ្គាំងឆ្គងទាំងឡាយដែលតែងតែមានក្រោយការបកប្រែ។ ប៉ុន្តែ ចំនុចដែលសំខាន់នោះ គឺថាយើងមានបន្ថែមនូវការអត្ថាធិប្បាយបន្ថែមពីលើសេចក្តីក្នុងព្រះគម្ពីរ ដើម្បីឱ្យអ្នកអាន អ្នកសិក្សា ឬបូជាចារ្យរឹតតែយល់អំពីអត្ថន៏យក្នុងព្រះគម្ពីរ"។

ផាត សំភី

## ការផ្សព្វផ្សាយព្រះគម្ពីរ

ព្រះគម្ពីរជាសៀវភៅដែលប្រមូលផ្តុំនូវគ្រប់រឿងរ៉ាវរបស់គ្រិស្តសាសនា និងត្រូវបានគេបកប្រែច្រើនបំផុត។ ព្រះគម្ពីរក៏ជាសៀវភៅដែលគេផ្សព្វផ្សាយច្រើនបំផុតផងដែរ ដោយមានប្រហែលជា ៥០លានក្បាលក្នុងមួយឆ្នាំៗនៅលើពិភពលោក។

ទស្សនៈ

# ប្រជាធិបតេយ្យមានសង្គមបើកចំហ

**សព្វថ្ងៃនេះ លទ្ធិប្រជាធិបតេយ្យកំពុងត្រូវបានពេញនិយមពីសំណាក់ប្រទេសជាច្រើន។ តើលទ្ធិនេះមានប្រវត្តិ និងគោលគំនិតយ៉ាងដូចម្តេចខ្លះមកលើសង្គម?**

### ប្រវត្តិសាស្ត្រខ្លី

គំនិតប្រជាធិបតេយ្យបានចាប់កំណើតនៅប្រទេសក្រិកតាំងពីយូរលង់ណាស់មកហើយ។

លទ្ធិនេះកើតឡើងដោយការជួបប្រជុំគ្នាស្ទើរតែជារៀងរាល់ថ្ងៃរបស់មនុស្ស និងប្រជាពលរដ្ឋមួយចំនួន ក្នុងការចូលរួមសំរេចកិច្ចការផ្សេងៗនៅក្នុងបុរី។ យើងហៅការជួបប្រជុំទាំងនេះតាមភាសាក្រិកថា Agora។

ប្រទេសអង់គ្លេសបានប្រកាន់យកលទ្ធិប្រជាធិបតេយ្យជាលើកដំបូងនៅសតវត្សរ៍ទី១៧។ ជាងមួយសតវត្សរ៍ក្រោយមកលទ្ធិនេះបានកើតមាននៅសហរដ្ឋអាមេរិក គឺនៅក្នុងឆ្នាំ ១៧៧៦ និងនៅប្រទេសបារាំងក្នុងឆ្នាំ១៧៨៩។ ប្រទេសផ្សេងៗទៀតក្នុងពិភពលោកត្រូវរង់ចាំរហូតដល់សតវត្សរ៍ទី ២០ ទើបបានស្គាល់លទ្ធិប្រជាធិបតេយ្យ។

### តើអ្វីទៅជាលទ្ធិប្រជាធិបតេយ្យ?

លទ្ធិប្រជាធិបតេយ្យគឺជាការរៀបចំរួមរស់ជាមួយគ្នា រវាងប្រជាពលរដ្ឋក្នុងសង្គមសន្តិភាព ដែលក្នុងនោះត្រូវមានកិច្ចពិភាក្សាជាអចិន្ត្រៃយ៍ ត្រូវបានធ្វើឡើងដោយមិននាំទៅដល់អំពើហិង្សា។ លទ្ធិប្រជាធិបតេយ្យពិតប្រាកដគឺត្រូវធានាឱ្យ

# ជំនួបរបស់ សៀកខ្មែរ

**កាលពីដើមខែវិច្ឆិកា ឆ្នាំ២០០៤ សិល្បករសៀកខ្មែរគ្រប់ទិសទីបានមកជួបជុំគ្នានៅទីក្រុងភ្នំពេញ។ នេះជាព្រឹត្តិការណ៍ដ៏កំរមួយសំរាប់មហាជន។**



ទស្សនីយភាពបង្វិលកងរបស់សមាគមហ្វារពន្លឺសិល្បៈ ជាក្រុមសៀកមកពីខេត្តបាត់ដំបង។

Photo: Davith

ជំនួបរយៈពេលពេញមួយសប្ដាហ៍ នៅមជ្ឈមណ្ឌលវប្បធម៌ជាតិនេះត្រូវបានរៀបចំដោយមជ្ឈមណ្ឌលវប្បធម៌បារាំង។ គំនិតនៃការរៀបចំទស្សនីយភាពនេះឡើងគឺដើម្បីស្រោចស្រង់ទំរង់សិល្បៈសៀកដែលមាននៅសេសសល់ពីការបាត់បង់។ ព្រឹត្តិការណ៍នេះឆ្លុះបង្ហាញឱ្យឃើញនូវជំហានថ្មីមួយក្នុងការចងក្រងសិល្បៈសៀកខ្មែរឱ្យមានជីវិតរស់ឡើងវិញ។ ក្នុងនោះផងដែរ ក្រុមសៀកបារាំង "បារ៉ូដេវែល " ក៏បានចូលរួមសម្ដែងផងដែរដើម្បីផ្លាស់ប្ដូរបទពិសោធន៍គ្នាទៅវិញទៅមកតាមរយៈការបង្កើតជាថ្នាក់រៀនមួយក្នុងរយៈពេលជួបជុំគ្នានោះ។ សិល្បករចំនួន២០០នាក់ បានមកចូលរួមក្នុងកម្មវិធីដ៏កំរមាននេះ ដោយក្នុងនោះ មានសិល្បករចំនួន១២៥នាក់បានផ្លាស់ទីមកពីខេត្តនានា។ ការស្នាក់នៅភ្នំពេញរបស់ពួកគេគឺដើម្បីធ្វើការផ្លាស់ប្ដូរនូវបទពិសោធន៍ និងបច្ចេក-ទេសក្នុងការសម្ដែងដល់គ្នាទៅវិញទៅមក។

នៅប្រទេសកម្ពុជា សៀកជាសិល្បៈដែលមានទំរង់ខុសៗគ្នា ហើយពុំសូវទទួលបាននូវការផ្សព្វផ្សាយ ឱ្យបានទូលំទូលាយដល់ហ្វូងមហាជនទេ។ "មួយសប្ដាហ៍នៃសិល្បៈសៀក" នៅភ្នំពេញគឺជាឱកាសមួយដ៏ល្អសំរាប់ប្រមូលផ្ដុំសាលាសៀក ក្រុមសៀក និងក្រុមអ្នកគ្មានអាជីព ប៉ុន្តែ មានចំណូលចិត្តសម្ដែងសៀក។ តាមរយៈព្រឹត្តិការណ៍នេះបានបង្ហាញឱ្យឃើញនូវភាពសំបូរបែបរបស់សៀកបុរាណខ្មែរ និងគំនិតច្នៃប្រឌិតថ្មីៗ។ ដោយសារការចូលទស្សនាឥតគិតថ្លៃ កៅអីចំនួន១០០០កន្លែង គ្មាននៅសល់ទំនេរមួយណាឡើយ។

បូលីន ដារិដ

## ក្រុមហ្វារពន្លឺសិល្បៈ

ទស្សនីយភាពរបស់សមាគមហ្វារពន្លឺសិល្បៈច្រើនតែទាក់ទងនឹងវប្បធម៌បូរាណ និងសម័យ។ ក្រៅពីសម្ដែងតាមទំលាប់ធម្មតា ក៏មានលាយភាពកំប្លែងផងដែរ។ ក្រុមនេះតែងបានទទួលនូវការកោតសរសើរជានិច្ច។

ប្រជាពលរដ្ឋមាននូវសន្តិភាពស៊ីវិលនិងសង្គម។ ក្នុងនោះត្រូវមានផងដែរនូវការរៀបចំបោះឆ្នោតដោយសេរី និងដោយគ្មានការក្លែងបន្លំដើម្បីជ្រើសរើសថ្នាក់ដឹកនាំ។

ពាក្យប្រជាធិបតេយ្យបានន័យថាយើងត្រូវមាននូវៈ

សេរីភាពខាងការគិតអំពីអ្វីៗទាំងអស់ ឬស្ទើរតែគ្រប់អ្វីៗគ្រប់យ៉ាងដែលគេត្រូវការគិត ដើម្បីបង្ហាញនូវទស្សនៈ ឬគំនិតរបស់ខ្លួន ព្រមទាំងជំនឿលើអ្វីដែលគេចង់ជឿ ទោះជាឯកជនក្ដី ឬជាក្រុមក្ដី។

សេរីភាពខាងការធ្វើសកម្មភាព ទោះបីមិនបានគ្រប់យ៉ាងឬគ្រប់អ្វីៗ ប៉ុន្តែ ប្រាកដជាបានច្រើនរឿង ដោយសារតែ យើងមិនមែនរស់នៅតែម្នាក់ឯងនៅក្នុងសង្គមនោះទេ។

សេរីភាពខាងការសម្ដែងនូវសកម្មភាពក្នុងការប្រព្រឹត្តិ និងការផ្ដួចផ្ដើមគំនិតបានច្រើនយ៉ាងក្នុងជីវិត និងសំរាប់ជីវិត។

សេរីភាពខាងសារព័ត៌មានដែលអាចធ្វើការពន្យល់ អត្ថាធិ-ប្បាយ និងរិះគន់លើការងារ សកម្មភាព ការសំរេចចិត្ត និងការប្រព្រឹត្តិរបស់រដ្ឋាភិបាល ដែលនេះអាចជាលក្ខខណ្ឌអនុ-គ្រោះ ឬធ្វើឱ្យមានការវិវត្តន៍ជាវិជ្ជមានដល់សង្គម។

សិទ្ធិ និងសេរីភាពក្នុងការបង្កើតអង្គការ និងការជួបជុំនយោបាយ និងសង្គមរបស់ប្រជាពលរដ្ឋរវាងគ្នានិងគ្នា។

សេរីភាពលើការប្រកួតប្រជែងដោយគ្មានការបន្លំ និងដោយគ្មានអំពើហិង្សាលើគ្រប់វិស័យទាំងអស់។

នៅមានត

## ចំនួនប្រទេសប្រជាធិបតេយ្យ

បើគិតតាមលក្ខណៈវិនិ-ច្ឆ័យនៃរបបសេរីពហុបក្សប្រទេសតិចជាង១០០ ក្នុងចំណោមប្រទេសជាង ២២៧លើលោកកាន់លទ្ធិប្រជាធិបតេយ្យ។ ប៉ុន្តែប្រទេសប្រជាធិបតេយ្យពិតប្រាកដមានមិនច្រើនជាង៣០ប្រទេសឡើយ។

# ល្បែងកំសាន្ត



តើកូនស្វាក្រិសមួយក្បាលនេះនឹងស៊ីអ្វី?
ដើម្បីអាចដឹងបាន សូមជួយឱ្យវាឆ្លងពីដុំថ្មមួយ ទៅដុំថ្មមួយទៀត តាមលំដាប់ពណ៌ ក្រហម ខៀវ និង ពណ៌លឿង ។



គំនូរ : ក. ចំរុង ពិសី

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ អូមែរ ហ្សីរ៉ាល់ដូ